# ជំងឺគ្រុនដាំង
# Dengue Fever



**ដំបូន្មានសំរាប់បុគ្គលិកថែទាំសុខភាពបឋម** **Advice for Primary Health Care Staff**

WORLD HEALTH ORGANIZATION

ដោយសាររដូវជំងឺគ្រុនដាំងបានចូលមកដល់ មជ្ឈមណ្ឌលជាតិប្រយុទ្ធជំងឺគ្រុនចាញ់ សូមរំលឹកដល់បុគ្គលិកថែទាំសុខភាពបឋមទាំងអស់ អំពីការពិនិត្យនិងការព្យាបាលករណីជំងឺនេះ ដូចខាងក្រោម ។

## ពិនិត្យគ្រប់កុមារទាំងអស់ដែលមានគ្រុនក្តៅ ដើម្បីរកមើលសញ្ញានៃជំងឺគ្រុនដាំង:

- គ្រុនក្តៅខ្លាំង ភ្លាមៗ និងមានរោគសញ្ញា ២ ឬ ច្រើន ដូចខាងក្រោម :
  - មុខក្រហម និង/ឬភ្នែកក្រហម ឬ
  - ឈឺក្បាលខ្លាំង ឬ
  - ឈឺនៅខាងក្រោយគ្រាប់ភ្នែក ឬ
  - ឈឺសន្លាក់ និងសាច់ដុំខ្លាំង ឬ
  - ចង្អោរ និងក្អួត ឬ
  - ស្នាមកន្ទួលក្រហមលើស្បែក ឬ
  - រោគសញ្ញានៃការហូរឈាមមួយចំនួន ដូចជា ស្នាមក្រហមអុចៗនៅលើស្បែក និងសញ្ញាឡាសេ (Lacet) វិជ្ជមាន ជាដើម ។
- ព្យាបាលគ្រុនក្តៅដោយការជូតខ្លួនជាមួយនឹងកន្សែងសើម និងការប្រើប្រាស់ថ្នាំប៉ារ៉ាសេតាម៉ុលក្នុងកំរិតយ៉ាងត្រឹមត្រូវ ។
- ចូរឱ្យអ្នកជំងឺផឹកទឹក និងទឹកអូរ៉ាលីត ។

As the dengue season has now started, CNM would like to take this opportunity to remind health staff about the diagnosis and management of cases of dengue.

## Check all children with fever for possible symptoms and signs of dengue fever

- Acute and high fever with 2 or more signs and symptoms as below:
  - Flushed face and/or injection conjonctival, or
  - Severe headache, or
  - Pain behind the eye or,
  - Severe joint and muscle pain or,
  - Nausea and vomiting or,
  - Cutaneous rash or
  - Haemorrhagic manifestations: petechiae, Tourniquet test +



- Treat fever with sponging and appropriate use of dose of paracetamol.
- Give oral fluids and Oral rehydration salt.

**!**

**ចូរប្រុងប្រយ័ត្នចំពោះការប្រើថ្នាំប៉ារ៉ាសេតាម៉ុលញឹកញាប់ពេក** - ការប្រើថ្នាំប៉ារ៉ាសេតាម៉ុលច្រើនពេក អាចបណ្តាលឱ្យមានបញ្ហាដល់ថ្លើម និងធ្វើឱ្យករណីជំងឺគ្រុនឈាមធ្ងន់ធ្ងរ កាន់តែពិបាកព្យាបាល ។

**Be careful about giving Paracetamol too often** – too much Paracetamol can cause liver problems and make severe dengue haemorrhagic fever difficult to manage.

**មិនត្រូវប្រើថ្នាំអាស្ពីរីន ឬថ្នាំប្រឆាំងការរលាកដែលមិនមែនជាស្តេរ៉ូអ៊ីត (NSAID) ដ៏ទៃទៀត ដូចជា អ៊ីប៊ុយប្រូហ្វែន ប្រសិនបើលោកអ្នកសង្ស័យថាជាជំងឺគ្រុនដាំង ឬជំងឺគ្រុនឈាម ។** ថ្នាំទាំងនេះ អាចបណ្តាល ឱ្យមានការរលាកក្រពះ និង/ឬអាចធ្វើឱ្យមានការហូរឈាមកាន់តែខ្លាំង ។ ចំពោះកុមារ វាអាចវិវត្តទៅជាចង្កោមរោគសញ្ញារិយ (Reye's syndrome) រលាកស្រោមខួរ និងមានផលវិបាកធ្ងន់ធ្ងរ ។

**Do not give Aspirin or other NSAID e.g. Ibuprofen if you suspect dengue** – these medicines can cause gastritis and/or make bleeding worse. In children, Reye's syndrome: encephalopathy, serious complication.





## ចំពោះកុមារដែលមានសភាពធ្ងន់ធ្ងរ (មានជំងឺគ្រុនឈាម)

- ប្រសិនបើកុមារស្ថិតក្នុងស្ថានភាពស៊ុក (shock) (ត្រជាក់ចុងដៃ ចុងជើង ជីបចរខ្សោយ និងញាប់ មានការហូរឈាម សន្លប់បាត់ស្មារតី):
  - ត្រូវចាប់ផ្តើមឱ្យសេរ៉ូមភ្លាម រួចបញ្ជូនទៅមន្ទីរពេទ្យបង្អែកជាបន្ទាន់

## For the very ill child (dengue haemorrhagic fever)

- If the child is in shock – (cold hands, weak and fast pulse, bleeding, unconscious)
  - Start IV fluids then refer immediately to Referral Hospital

**ប្រសិនបើលោកអ្នកឱ្យសេរ៉ូម ត្រូវប្រយ័ត្នកុំឱ្យលើសចំណុះ ។** ការឱ្យសេរ៉ូមលើសចំណុះ អាចបណ្តាលឱ្យជំងឺគ្រុនឈាម មានសភាពកាន់តែធ្ងន់ធ្ងរឡើង ដូចជា ការហើមសួត ហើយធ្វើឱ្យពិបាកព្យាបាល ។

**If you give IV fluids be careful not to fluid overload** - IV fluid overload can make severe dengue haemorrhagic fever such as pulmonary oedema, difficult to manage.

❖ ប្រសិនបើសង្ស័យថាជាករណីជំងឺគ្រុនឈាម ត្រូវបញ្ជូនទៅមន្ទីរពេទ្យបង្អែកជាបន្ទាន់។



រោគសញ្ញាដែលអាចធ្វើឱ្យមានការសង្ស័យ មានដូចជា :

- គ្រុនក្តៅខ្លាំង ឬបាត់គ្រុនក្តៅហើយ តែកុមារនៅតែមានសភាពធ្ងន់ធ្ងរ
- ឈឺពោះ
- ឡេះឡុះ ឬសន្លឹម
- មានសញ្ញានៃការហូរឈាមណាមួយ ខាងក្រោមនេះ :
  - ក្អួតមានលាយឈាម
  - លាមកមានឈាម
  - ហូរឈាមតាមច្រមុះ ឬ អញ្ចាញធ្មេញ
  - ស្នាមកន្ទួលក្រហមៗនៅលើស្បែក
- ទោះបីជាកុមារមិនទាន់មានរោគសញ្ញាស្កុកក៏ដោយ

❖ Any suspected dengue haemorrhagic fever cases need to be referred to the Referral Hospital.

Signs and symptoms that lead to suspecion are:

- high fever or fever gone but child very ill
- Abdominal pain
- irritable or lethargic
- any signs of bleeding
  - blood in vomit
  - blood in stools
  - bleeding from nose or gums
  - petechiae
- child: even not yet in shock condition



*ហូរឈាមតាមច្រមុះ ឬ អញ្ចាញធ្មេញ*
*bleeding from nose or gums*



*លាមកមានឈាម* *blood in stools*



*ក្អួតមានលាយឈាម* *blood in vomit*